# ឧបសម្ព័ន្ធ

Draft

# ឧបសម្ព័ន្ធ-១

**ផែនទី-១ ផែនទីបង្ហាញទីតាំងឡូតិ៍គំរូពង្រាយតាមគោលការណ៍ចៃដន្យ**

១-២:តារាង-១: ទំហំរបស់ឡូតិ៍ និងដើមឈើ ដែលត្រូវបានវាស់វែងនៅក្នុងឡូតិ៍គំរូ

១-២តារាងទី-២: Field Datasheets for Biomass Measurement

Draft

# ឧបសម្ព័ន្ធ ១

## ១-១ ផែនទី-១ ផែនទីបង្ហាញទីតាំងឡូតិ៍គំរូពង្រាយតាមគោលការណ៍ចៃដន្យ




| ID-plot survey points | | | | | |
|---|---|---|---|---|---|
| 1 | 353500 | 1269500 | 20 | 351594 | 1273501 |
| 2 | 354446 | 1270099 | 21 | 352314 | 1273583 |
| 3 | 354495 | 1269505 | 22 | 353315 | 1273503 |
| 4 | 353417 | 1270627 | 23 | 351773 | 1270701 |
| 5 | 355499 | 1269505 | 24 | 351506 | 1272720 |
| 6 | 356483 | 1269533 | 25 | 354366 | 1270748 |
| 7 | 355503 | 1268500 | 26 | 354787 | 1272555 |
| 8 | 356502 | 1268501 | 27 | 355500 | 1271636 |
| 9 | 355490 | 1267501 | 28 | 353336 | 1272581 |
| 10 | 356499 | 1267492 | 29 | 353836 | 1271348 |
| 11 | 356510 | 1270505 | 30 | 355679 | 1270458 |
| 12 | 357506 | 1270550 | 31 | 354337 | 1271891 |
| 13 | 356500 | 1271500 | 32 | 352535 | 1271368 |
| 14 | 357500 | 1271500 | 33 | 352674 | 1269615 |
| 15 | 356500 | 1272500 | 34 | 352102 | 1268667 |
| 16 | 357500 | 1272500 | 35 | 352340 | 1267049 |
| 17 | 355109 | 1270109 | 36 | 353789 | 1266330 |
| 18 | 354518 | 1267324 | 37 | 353962 | 1267299 |
| 19 | 354500 | 1270500 | 38 | 352645 | 1266515 |

## ១-២:តារាង-១: ទំហំរបស់ឡូតិ៍ និងដើមឈើ ដែលត្រូវបានវាស់វែងនៅក្នុងឡូតិ៍គំរូ

| | Nested plot dimensions | Area/ha | Tree sizes recorded (cm DBH) |
|---|---|---|---|
| Saplings | 3m by 3m | 0.001 | stems <5 cm dbh; height > 1.3 m. Count vegetation individual. |
| Small subplot | 7m by 7m | 0.005 | 5-20 cm |
| Medium subplot | 25m by 25m | 0.063 | >20-50 cm |
| Large subplot | 35m by 35m | 0.123 | >50 cm |

DBH : Diameter at Breath Height, standardized at 1.30 m above ground level




រូបភាព-១: ឡូតិ៍រាងការេ

## ១-២តារាងទី-២: Field Datasheets for Biomass Measurement

### FIELD DATA SHEET FOR BIOMASS MEASUREMENT

Page:_____of_____

Plot ID #:______________Location: GPS Waypoint #: N: E:

Forest type:________________________________________

Date:___/___/____ Data recorded by:________________________________________

# people in crew: ____________ Crew chief: ________________________________________

Start Time: ________________ End time: ________________ Total Time: ________________________________

Slope (%): ________________________________________________________

Notes:

Nested Plot dimensions (m): small: 7m by 7 m medium: 25m by 25 m large: 35m by 35m

Saplings (less than 10 cm DBH, greater than 1.3 meters Height. It was measure only if in very young forest or the situation calls for it)

| Species | Main Plot samples (35m by 35m) | | | | | | | | Remarks |
|---|---|---|---|---|---|---|---|---|---|
| | 3m*3m DBH<5cm, >1.3 m h | | 7m*7m DBH 5-20 cm | | 25*25 DBH 21-50cm | | 35m*35m ( DBH>50cm) | | |
| | DBH (cm) | # trees | DBH (cm) | # trees | DBH (cm) | # trees | DBH (cm) | # trees | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

Draft

## Annex-1-5: Field Datasheets for Fauna Survey

Page:_____of_____

### FIELD DATA SHEET FOR WILDLIFE OCCUPANCY SURVEY

UTM Start:____________________ UTM End:____________________ Location: ______________________________________

Start Time: _______________ End time: _______________ Total Time: ______________________________________

# people in crew: ____________ Crew chief: ________________________________________________

Forest type:________________________________________________________________________

Date:______/______/___________ Data recorded by:________________________________________________

| No | UTM Reference # in GPS | Mammal | Bird | Reptile | No | Type of Observation | | | Habitat | site seen name | Remarks |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Seen | Track | Vocaliz ation | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

Draft

# ឧបសម្ព័ន្ធ~៣

៣-១ លទ្ធផលវិភាគរ៉ែនៅមន្ទីរពិសោធន៍ SGS Singapore និង ម៉ាឡេស៊ី

៣-២ ឯកសារលិខិតបទដ្ឋាន

Draft

# ឧបសម្ព័ន្ធ៣-១

## លទ្ធផលវិភាគនៅមន្ទីរពិសោធន៍ SGS Singapore និង ម៉ាឡេស៊ី

SGS

**TEST REPORT**

Report No. : CH:GL:7110023884 DATE : 31/10/2007

JOE No. : 711110960 Report Control No.:7115024975 10104530

**SAMPLE NOT DRAWN BY LABORATORY**

SAMPLE SUBMITTED AND IDENTIFIED BY SUPPLIER AS : ILMENITE

| | |
|---|---|
| COMPANY NAME | SGS TESTING & CONTROL SERVICES SINGAPORE PTE LTD. |
| ADDRESS | 26 AYER RAJAH CRESCENT #07-07 |
| CITY | 139944 |
| SAMPLING METHOD | N.A. |
| SAMPLE DESCRIPTION | ILMENITE |
| SAMPLE QTY. | 1/2 KG |
| CUSTOMER APPL NO. | 10104530 |
| SAMPLE RECD ON | 22-10-2007 |
| TEST START DATE | 22/10/2007 |
| TEST END DATE | 31/10/2007 |

| TESTS | PROTOCOL | RESULT |
|---|---|---|
| Calcium as Ca | IS:9788:1981 | 0.085% |
| Ferric Iron as Fe | IS:9788:1981 | 37.60% |
| Ferrous Iron as Fe | IS:9788:1981 | 21.43% |
| Magnesium as Mg | IS:9788:1981 | 2.01% |
| Silica as SiO2 | IS:9788:1981 | 0.06% |
| Titanium as TiO2 | IS:9788:1981 | 45.01% |

***** End of Report ****

Draft

This is a computer generated report hence signature is not available



This document is issued by the Company under its General Conditions of Service accessible at http://www.sgs.com/terms_and_conditions.htm Attention is drawn to the limitation of liability, indemnification and jurisdiction issues defined therein.Any holder of this document is advised that informationcontained hereon reflects the Company's findings at the time of its intervention only and within the limits of customer's instructions, if any. The Company's sole responsibility is to its Customer and this document does not exonerate parties to a transaction from exercising all their rights and obligations under the transaction documents. Any unauthorized alteration, forgery or falsification of the content or appearance of this document is unlawful and offenders may be prosecuted to the fullest extent of the law.

SGS India Pvt. Ltd. | Laboratory, 1/509 A, Old Mahabalipuram Road, Thoraipakkam, Chennai-600 097 Phone : 91-44-24963344/24962822, Fax : 91-44-24963075
Regd & Corp. Off SGS House, 4B, A S Marg, Vikhroli (West), Mumbai-400083. Tel : (022) 25798421 to 28 Fax : (022) 25798431 to 35 www.sgs.com

Member of the SGS Group

MULTI MINERALS LABORATORY SERVICES (1296357-A)
Lot 137, Jalan Batu Caves
(Next to Masjid Amaniah)
68100 Batu Caves, Selangor D. E.
Tel : 03-61897939, 61898252
Fax : 03-61888785

# TEST REPORT

Client:

KAYFOUR DEV.CORP. SDN BHD
53-2, Jalan 2 / 27F
Pusat Bandar Wangsa Maju
53300 Kuala Lumpur

Report No. : 05/MML/3651
Date Received : 24.11.2005
Date Report : 05.12.2005
Page : 1 of 1

| Sample described as | | | | Granular Concentrate |
|---|---|---|---|---|
| Marking | | | | COMBODIAN |
| Iron | as | FeO | % (w/w) | 31.0 |
| Iron | as | $Fe_2O_3$ | % (w/w) | 20.4 |
| Titanium | as | $TiO_2$ | % (w/w) | 45.2 |

Approved Signatory : ..................................
AZIZAH BINTI ABDUL GHANI
(Chemist)

*Note : Reported results refer to submitted sample (s) only.*

Draft

# ឧបសម្ព័ន្ធ៣-២

## ឯកសារលិខិតបទដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ [illegible] ឧរថ.ធរ.អប.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៧

## អាជ្ញាប័ណ្ណស្វែងរុករក

---

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខៈ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែ Ilmenite នៅតំបន់អូរតាគុត ស្រុកថ្មបាំង ខេត្តកោះកុង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd ។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករក លេខៈ៨៨៩ ឧរថ.ធរ.អប ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតស្នើសុំ ចុះថ្ងៃទី២៨ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd ។

### <u>សម្រេច</u>

**<u>ប្រការ១:</u>** អនុញ្ញាតអោយក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd មានអាសយដ្ឋានផ្ទះ លេខ១៣ ផ្លូវលេខ ៥៥៦ សង្កាត់បឹងកក់ ខណ្ឌទួលគោករាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរ៉ែ Ilmenite នៅតំបន់អូរតាគុត

G samnang rea 07

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥)២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard. Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263

COPY
Draft

ស្រុកថ្មបាំង ខេត្តកោះកុង លើផ្ទៃដីទំហំ១២០ គីឡូម៉ែត្រក្រឡា ដែលមានកូអ័រដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោណេ | ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|---|---|---|
| A | $350^{000}$ | $1276^{000}$ | C | $360^{000}$ | $1264^{000}$ |
| B | $360^{000}$ | $1276^{000}$ | D | $350^{000}$ | $1264^{000}$ |

**ប្រការ២:** ក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd ត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែលើផ្ទៃដី ដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និង កម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេក-ទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

**ប្រការ៣:** អាជ្ញាប័ណ្ណនេះមានសុពលភាពរហូតដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងករណីដែលក្រុមហ៊ុននៅតែមិនអាចសិក្សា និង វាយតម្លៃប្រសិទ្ធភាពសេដ្ឋកិច្ចនៃជំរករ៉ែនៅតំបន់សម្បទានរបស់ខ្លួន ដើម្បីឈានទៅធ្វើអាជីវកម្មបានទេ ក្រសួងនឹងបញ្ចប់កិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែ Ilmenite នៅតំបន់ខាងលើ ។

**ប្រការ៤:** ក្នុងករណីប្រព្រឹត្តល្មើសលើលក្ខខណ្ឌ នៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ៥:** អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តកោះកុង និង ប្រធានក្រុមហ៊ុន Samnang Rea Thbong Thmor Co., Ltd ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារៈកិច្ច រៀងៗខ្លួន ។

**ប្រការ៦:** អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ
- សាលាខេត្តកោះកុង
- សាលាស្រុកថ្មបាំង
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

G samnang rea 07

Draft

# អនុស្សារណៈ ស្តីពីការសិក្សាស្វែងយល់ជំរករ៉ែ *Ilmenite($FeTiO_3$)*
# នៅតំបន់ អូរតាគុត ស្រុក ថ្មបាំង ខេត្ត កោះកុង

អនុស្សារណៈនេះត្រូវបានធ្វើឡើងនៅថ្ងៃទី ... ឆ្នាំ២០០៤ រវាង **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** ហៅកាត់ថា "**ក្រសួង**" និង ក្រុមហ៊ុន **សំណង់រ៉ែ ត្បូងថ្ម អាហារ៉ែណា-នីហារ៉ែណា និង អភិវឌ្ឍន៍** ជាក្រុមហ៊ុនមួយដែលបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហៅកាត់ថា "**ក្រុមហ៊ុន**" ។

- *ដោយហេតុថា ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០១ បានប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងអាជីវកម្មធនធានរ៉ែ ។*
- *បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។*
- *ដោយហេតុថា ក្រុមហ៊ុនបានដាក់ពាក្យស្នើសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវ និង អាជីវកម្មរ៉ែធនធានរ៉ែលោហៈ នៅតំបន់ថ្មបាំង ខេត្ត កោះកុង យោងលិខិតរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤ និងលិខិតចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ។*

**ដូច្នេះ ភាគីទាំងពីរយល់ព្រមដូចតទៅ :**

**ប្រការ ១ ៈ**

កម្មវត្ថុនៃអនុស្សារណៈនេះគឺការសិក្សាស្វែងយល់លក្ខណៈភូគព្ភសាស្ត្រជំហានដំបូងនៃតំបន់ជំរករ៉ែ *Ilmenite ($FeTiO_3$)* ដែលមានទីតាំងស្ថិតនៅតំបន់ **អូរតាគុត ស្រុក ថ្មបាំង ខេត្ត កោះកុង** ។ កូអរដោណេរបស់តំបន់នេះត្រូវបាន កំណត់ក្នុងឧបសម្ព័ន្ធទី ១ និង ផែនទីទីតាំង ត្រូវកំណត់ ក្នុងឧបសម្ព័ន្ធទី ២ ។

**ប្រការ ២ ៈ**

ក្រសួងយល់ព្រមអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការសិក្សាស្វែងយល់លក្ខណៈភូគព្ភសាស្ត្រជំហានដំបូង នៃជំរករ៉ែ *Ilmenite* នៅតំបន់ខាងលើ ដើម្បីកំណត់ទីតាំង និងមានមូលដ្ឋានសំរាប់ក្រុមហ៊ុនធ្វើការពិចារណា ដើម្បីដាក់ពាក្យសុំអាជ្ញាប័ណ្ណស្វែងរុករកនៅពេលអនាគត ។ ក្នុងរយៈពេលនៃអនុស្សារណៈនេះក្រសួងមិនអនុញ្ញាតអោយក្រុមហ៊ុនធ្វើការជីក ឬ ខួងយកសំណាករ៉ែជាទ្រង់ទ្រាយធំនាំអោយប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថានទេ ។

ក្រុមហ៊ុនមិនអាចប្រើប្រាស់អនុស្សារណៈនេះដើម្បីគោលបំណងផ្សេងទៀត ក្រៅពីការសិក្សាស្វែងយល់ជំរករ៉ែ *Ilmenite* បានទេ ។ ក្នុងករណីការសិក្សាស្រាវជ្រាវនោះបានជួបប្រទះរ៉ែផ្សេងៗទៀត ដូចជាត្បូងថ្មជាដើម ក្រុមហ៊ុនត្រូវរាយការណ៍មកក្រសួងជាបន្ទាន់ ហើយមិនត្រូវធ្វើសកម្មភាពជីកយករ៉ែត្បូងនៅក្នុងតំបន់នោះទេ ។

**ប្រការ ៣ ៈ**

ក្រុមហ៊ុនត្រូវសហការជាមួយក្រសួងដើម្បីដាក់ចេញនូវកម្មវិធីការងារ និងគំរោងនានាដែលត្រូវអនុវត្ត ដែលរួមមាន :

១ - ការកំណត់ទីតាំងដែលត្រូវធ្វើការសិក្សាពីជំរករ៉ែ *Ilmenite* និងកាលវិភាគការងារ

២ -ការប្រមូលទិន្នន័យ និងរបាយការណ៍បច្ចេកទេសដែលត្រូវរៀបចំឡើង

៣ - កម្មវិធីបណ្តុះបណ្តាល និងការផ្ទេរបច្ចេកវិទ្យា និង

៤ - កម្មវិធីការងារពាក់ព័ន្ធផ្សេងទៀត ។

**ប្រការ ៤ ៈ**

ប្រសិនបើក្រុមហ៊ុនមិនបានចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវនៅក្នុងតំបន់នេះនៅក្នុងកំឡុងពេល៦០(ហុកសិប) ថ្ងៃ បន្ទាប់ពីអនុស្សារណៈត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរទេ អនុស្សារណៈនេះនឹងត្រូវចាត់ទុកជាមោឃៈ ។

**ប្រការ ៥ ៈ**

ក្រុមហ៊ុនយល់ព្រមទទួលបន្ទុកចំណាយ និង ការខាតបង់ទាំងអស់ដោយខ្លួនឯងផ្ទាល់ ព្រមទាំងផ្តល់បច្ចេកវិទ្យា និងកម្លាំងពលកម្មចាំបាច់ ដើម្បីធ្វើការសិក្សាពីជំរករ៉ែ *Ilmenite* នៅក្នុងតំបន់ដែលបានគ្រោងទុក ។

**ប្រការ ៦ ៈ**

ក្រុមហ៊ុនយល់ព្រមផ្តល់ការបណ្តុះបណ្តាលនៅនឹងកន្លែងសំរាប់បុគ្គលិករបស់អគ្គនាយកដ្ឋានធនធានរ៉ែ ចំនួន ពីរ (០២) រូប ដែលត្រូវផ្ទេរអោយទៅបំពេញភារកិច្ចបណ្តោះអាសន្នជាមួយក្រុមហ៊ុន ដើម្បីទទួលបទពិសោធន៍ ក្នុងវិស័យអភិវឌ្ឍន៍រ៉ែនៅកម្ពុជា ។ រយៈពេលនៃការចាត់តាំងបណ្តោះអាសន្នរបស់បុគ្គលិកទាំងនោះ ត្រូវអនុលោមទៅតាមការព្រមព្រៀងគ្នា។ ក្រុមហ៊ុនយល់ព្រមផ្តល់នូវប្រាក់កំរៃសមស្រប និងកន្លែងស្នាក់នៅសំរាប់បុគ្គលិក ដែលត្រូវបានចាត់បញ្ជូនឱ្យទៅបំពេញភារៈកិច្ចបណ្តោះអាសន្ននោះ ។

**ប្រការ ៧ ៈ**

អនុស្សារណៈនេះមានសុពលភាព ប្រាំមួយ (០៦) ខែ ចាប់ពីថ្ងៃចុះហត្ថលេខាលើអនុស្សារណៈនេះដោយភាគីទាំងពីរ ។

**ប្រការ ៨ ៈ**

ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ប្រចាំខែអំពីភាពជឿនលឿនទៅមុខមកក្រសួងអោយបានទៀងទាត់ ។

**ប្រការ ៩ ៈ**

ប្រសិនបើមានគ្រោះធម្មជាតិដែលមិនអាចជៀសបានដូចជាព្យុះ ឬទឹកជំនន់ជាដើម ហើយបានធ្វើឱ្យប៉ះពាល់ដល់ការសិក្សាស្វែងយល់អំពីជំរករ៉ែ *Ilmenite* រយៈពេលនៃគ្រោះធម្មជាតិនោះនឹងមិនត្រូវគិតបញ្ចូលទៅក្នុងរយៈពេលសុពលភាពនៃអនុស្សារណៈនេះឡើយ ក្នុងករណីក្រុមហ៊ុនបានដាក់សំណើសុំមិនបញ្ចូលរយៈពេលនោះជូនក្រសួង ដើម្បីពិនិត្យ និង សំរេចយ៉ាងហោចណាស់ដប់ប្រាំ (១៥) ថ្ងៃ បន្ទាប់ពីគ្រោះធម្មជាតិនោះបានបញ្ចប់សកម្មភាព ។



x

**ប្រការ ១០ ៖**

ក្រុមហ៊ុនយល់ព្រមថា ក្នុងកំឡុងពេលសាមសិប (៣០) ថ្ងៃ មុនអនុស្សារណៈនេះអស់សុពលភាព ក្រុមហ៊ុនត្រូវដាក់ជូនក្រសួងនូវរបាយការណ៍បច្ចេកទេស ទិន្នន័យនិងពត៌មាន ការវិភាគ និង បំណកស្រាយទិន្នន័យ ដែលទាក់ទងទៅនឹងការសិក្សាស្វែងយល់ពីជំរករ៉ែ *Ilmenite* នៅក្នុងតំបន់នោះ ដើម្បីធ្វើការពិនិត្យ និង ពិចារណា ។ អាស្រ័យទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ ក្រុមហ៊ុនអាចដាក់ពាក្យសុំអាជ្ញាប័ណ្ណស្វែងរុករកពីក្រសួង ។

អនុស្សារណៈនេះត្រូវបានធ្វើឡើងដោយភាគីទាំងពីរជាភាសាខ្មែរ និង ភាសាអង់គ្លេសដែលភាសានីមួយៗមានតំលៃ និងមានសុពលភាពស្មើគ្នាក្នុងការបកស្រាយ ប៉ុន្តែក្នុងករណីមានការខ្វែងគ្នារវាងភាសាទាំងពីរ អត្ថបទជាភាសាខ្មែរត្រូវចាត់ទុកជាគោល ។

ភាគីទាំងពីរបានចុះហត្ថលេខាលើអនុស្សារណៈនេះជាភាសាខ្មែរ និង ភាសាអង់គ្លេស នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃដូចបានកំណត់ខាងលើ មួយមុខៗចំនួន ២ច្បាប់ដើម ។

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

04 MAR 2005

**ស៊ុយ សែម**

រដ្ឋមន្ត្រី

**ក្រុមហ៊ុន សំណាងរ៉ែ ត្បូងថ្ម អាហារីណា-នីហារីណា និង អេរិចឡាន់**

04 MAR 2005

**លោក សាន ឈុនសុខ**

ប្រធានក្រុមហ៊ុន

Draft

## ឧបសម្ព័ន្ធទី ១

កូអ័រដោណេតំបន់សំរាប់ធ្វើការសិក្សាស្វែងយល់ពីជំរករ៉ែ *Ilmenite*

**នៅ តំបន់ អូរនាគុត ស្រុក ថ្មបាំង ខេត្តកោះកុង**

| ចំណុច | អាប់ស៊ីស ( ខ្នាត UTM ) | អ័រដោណេ ( ខ្នាត UTM ) |
|---|---|---|
| **A** | $3\,50^{00}$ | $12\,76^{00}$ |
| **B** | $3\,60^{00}$ | $12\,76^{00}$ |
| **C** | $3\,60^{00}$ | $12\,64^{00}$ |
| **D** | $3\,50^{00}$ | $12\,64^{00}$ |

ព្រំប្រទល់នៃតំបន់សំរាប់ធ្វើការសិក្សាពីជំរករ៉ែ ចាប់ផ្ដើមចេញពីចំណុច A ទៅ B ចេញពី B-C-D និងចេញពី D ទៅ A វិញ តាមខ្សែរបន្ទាត់ត្រង់ ។

តំបន់សំរាប់ធ្វើការសិក្សាពីជំរករ៉ែមានក្រឡាផ្ទៃសរុប ១២០( មួយរយម្ភៃ ) គីឡូម៉ែត្រក្រឡា ។

## ឧបសម្ព័ន្ធទី២

ផែនទីតំបន់សំរាប់ធ្វើការសិក្សាស្វែងយល់ពីជំរករ៉ែ *Ilmenite*

**តំបន់ អូរតាគុត ស្រុក ថ្មបាំង ខេត្ត កោះកុង**

( យកតាមផែនទីឋានានុលេខសន្លឹកលេខ ៥៧៣១ និង ៥៧៣២.ខ្នាត 1: 100 000)




*** ក្នុងករណីមានការខុសគ្នារវាងកូអរដោណេក្នុងឧបសម្ព័ន្ធទី១ និង ផែនទីក្នុងឧបសម្ព័ន្ធទី២ នេះ កូអរដោណេក្នុងឧបសម្ព័ន្ធទី១ ត្រូវយកជាគោល ។

# កិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែអ៊ីលម៉ានីត (ILMENITE) នៅតំបន់អូរតាគុត ស្រុកថ្មបាំង ខេត្តកោះកុង

2 9 NOV 2005

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើនៅថ្ងៃទី រវាង**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** (ហៅកាត់ថា "**ក្រសួង**") តំណាងឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ហៅកាត់ថា "**រាជរដ្ឋាភិបាល**") និង ក្រុមហ៊ុន SAMNANG REA THBONG THMOR CO., LTD. ជាក្រុមហ៊ុនមួយដែលបង្កើតឡើង និងឋិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (ហៅកាត់ថា "**អ្នកចុះកិច្ចសន្យា**")

- ដោយហេតុថា មាត្រា៥៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ ។ ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ដោយច្បាប់" ។
- ដោយហេតុថា ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ បានប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- ដោយហេតុថា អ្នកចុះកិច្ចសន្យាបានដាក់សំណើសុំវិនិយោគលើគំរោងសិក្សាស្រាវជ្រាវរ៉ែ អ៊ីលម៉ានីត (Ilmenite) នៅក្នុងតំបន់ អូរតាគុត ស្រុកថ្មបាំង ខេត្ត កោះកុង យោងលិខិតរបស់ក្រុមហ៊ុនលេខ 018 ចុះថ្ងៃ ទី ១២ ខែ តុលា ឆ្នាំ ២០០៥ ។
- ដោយហេតុថា អ្នកចុះកិច្ចសន្យាបានទទួលសេចក្តីយល់ព្រមជាគោលការណ៍ពីរាជរដ្ឋាភិបាល យោងលិខិតជូនដំណឹងលេខ ៣៣៤៤/០៥ គ.វ.ក ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- ដូច្នេះ តាមការព្រមព្រៀងគ្នា និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីទាំងពីរបានយល់ព្រមចំពោះការផ្តល់អាជ្ញាប័ណ្ណស្វែងរុករកធនធានរ៉ែដូចតទៅ ។

# ជំពូកទី ១

# ខ្លឹមសារ និងការបកស្រាយ

## ប្រការ ១ : ខ្លឹមសារ

១.១. កម្មវត្ថុនៃកិច្ចព្រមព្រៀងនេះគឺការសិក្សាស្រាវជ្រាវរ៉ែអ៊ីលម៉ានីត (Ilmenite) ហៅកាត់ថា "**ប្រតិបត្តិការរ៉ែ**" ដូចមានចែងលំអិតក្នុងកិច្ចព្រមព្រៀងនេះ ។

១.២. តំបន់ប្រតិបត្តិការរ៉ែមានផ្ទៃក្រឡាចំនួន ១២០ (មួយរយម្ភៃ)គីឡូម៉ែត្រក្រឡា ដែលឋិតនៅក្នុងតំបន់ អូរតាគុត ស្រុកថ្មបាំង ខេត្តកោះកុង ហើយដែលកូអ័រដោណេនៃតំបន់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១ និងផែនទីទីតាំងក្នុងឧបសម្ព័ន្ធ ២ ដូចមានភ្ជាប់មកជាមួយនេះហៅកាត់ថា "**តំបន់កិច្ចសន្យា**" ។

១.៣ រ៉ែអ៊ីលម៉ានីត (Ilmenite) នៅក្នុងកិច្ចព្រមព្រៀងនេះ ហៅកាត់ថា "**រ៉ែ**" ។

១.៤ ក្នុងករណីអ្នកចុះកិច្ចសន្យាបានរកឃើញរ៉ែផ្សេងទៀតក្រៅពីរ៉ែអ៊ីលម៉ានីត (Ilmenite) ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ ហើយមានបំណងធ្វើអាជីវកម្មជីកយករ៉ែទាំងនោះ អ្នកចុះកិច្ចសន្យាត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណរ៉ែពាក់ព័ន្ធផ្សេងទៀតដូចបានចែងនៅក្នុងបទបញ្ញត្តិ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

១.៥ អ្នកចុះកិច្ចសន្យាត្រូវទទួលខុសត្រូវចំពោះមុខក្រសួងនូវការអនុវត្តន៍ប្រតិបត្តិការរ៉ែ ដោយអនុលោមតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ និងក្រោមការត្រួតពិនិត្យរបស់ក្រសួង ។ អ្នកចុះកិច្ចសន្យា ជាអង្គភាពស្របច្បាប់មួយ ដែលមានសិទ្ធិអនុវត្តប្រតិបត្តិការរ៉ែដែលបានគ្រោងទុកនៅក្នុងតំបន់កិច្ចសន្យាក្នុងថេរៈវេលានៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែ ។

១.៦ អ្នកចុះកិច្ចសន្យាមិនមែនជាម្ចាស់កម្មសិទ្ធិលើតំបន់កិច្ចសន្យា ដែលបានកំណត់ក្នុងប្រការ ១.២ ខាងលើនេះឡើយ លើកលែងតែតំបន់ណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ភូមិបាលដែលមានជាធរមាន ។

១.៧ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ដើមទុន បច្ចេកវិទ្យា និង កំលាំងពលកម្មចាំបាច់ ដើម្បីអនុវត្តប្រតិបត្តិការរ៉ែដែលបានគ្រោងទុក លើកលែងតែមានសេចក្តីចែងផ្សេងទៀតក្នុងកិច្ចព្រមព្រៀងនេះ ។

១.៨ អ្នកចុះកិច្ចសន្យាត្រូវអនុវត្តប្រតិបត្តិការរ៉ែដែលបានគ្រោងទុកដោយទទួលការខាតបង់ និងចំណាយដោយខ្លួនឯងផ្ទាល់ លើកលែងតែមានសេចក្តីចែងផ្សេងទៀតក្នុងកិច្ចព្រមព្រៀងនេះ ។

១.៩ កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន ចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរហៅកាត់ថា "**កាលបរិច្ឆេទធរមាន**" ។

Draft

**ប្រការ ២ : ការបកស្រាយ**

ចំណងជើងដែលបានប្រើក្នុងកិច្ចព្រមព្រៀងនេះ គឺសំរាប់សំគាល់ដល់ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ ហើយមិនទាក់ទិនដល់ការបកស្រាយទេ ។

## ជំពូកទី ២
## ថេរវេលានៃកិច្ចព្រមព្រៀង

**ប្រការ ៣ : ថេរវេលានៃកិច្ចព្រមព្រៀង**

ថេរៈវេលានៃកិច្ចព្រមព្រៀងនេះមានសុពលភាពរហូតអាជ្ញាប័ណ្ណស្វែងរុករករ៉ែត្រូវបានបញ្ចប់ ។

**ប្រការ ៤ : ការបញ្ចប់កិច្ចព្រមព្រៀង**

ក្នុងករណីដែលអាជ្ញាប័ណ្ណស្វែងរុករករ៉ែត្រូវបានដកហូតក្រោមកិច្ចព្រមព្រៀងនេះដោយក្រសួង កិច្ចព្រម-ព្រៀងនេះនឹងត្រូវបានបញ្ចប់ដោយខ្លួនវាជាស្វ័យប្រវត្តិ ។

## ជំពូកទី ៣
## អាជ្ញាប័ណ្ណស្វែងរុករករ៉ែ

**ប្រការ ៥ : រយៈពេលស្វែងរុករករ៉ែ**

រយៈពេលស្វែងរុករករ៉ែ មានចំនួនប្រាំមួយ (០៦) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចរមាននៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែដំបូង ដែលបានចេញឱ្យអ្នកចុះកិច្ចសន្យា ។

**ប្រការ ៦ : លក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណស្វែងរុករករ៉ែ**

៦.១ បន្ទាប់ពីកាលបរិច្ឆេទចរមាននៃកិច្ចព្រមព្រៀងនេះក្នុងកំឡុងពេលហុកសិប (៦០) ថ្ងៃ អ្នកចុះកិច្ចសន្យាត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណស្វែងរុករករ៉ែដោយភ្ជាប់មកជាមួយនូវកម្មវិធីការងារស្វែងរុករករ៉ែ ដែលបានស្នើឡើងសំរាប់កិច្ចប្រតិបត្តិការរ៉ែ និងថវិកាសំរាប់កម្មវិធីការងារស្វែងរុករកនីមួយៗ ដែលអ្នកចុះកិច្ចសន្យាមានគំរោងអនុវត្តក្នុងរយៈពេលស្វែងរុករកដំបូង ។

៦.២ អាជ្ញាប័ណ្ណស្វែងរុករករ៉ែដែលត្រូវចេញឱ្យអ្នកចុះកិច្ចសន្យា មានសុពលភាពសំរាប់រយៈពេលពីរ (០២) ឆ្នាំ បន្ទាប់ពីកម្មវិធីការងារស្វែងរុករកដែលបានស្នើឡើងសំរាប់កិច្ចប្រតិបត្តិការរ៉ែ និង ថវិកាសំរាប់កម្មវិធីការងារស្វែងរុករកនីមួយៗ បានទទួលការយល់ព្រមពីក្រសួង ។

## ប្រការ ៧ : លក្ខខណ្ឌនៃការពន្យាបន្តអាជ្ញាប័ណ្ណស្វែងរុករករ៉ែ

៧.១ អាជ្ញាប័ណ្ណស្វែងរុករករ៉ែអាចពន្យាបានពីរ (០២) ដង ដោយម្តងៗមានរយៈពេលពីរ (០២) ឆ្នាំ ។ អាជ្ញាប័ណ្ណស្វែងរុករករ៉ែដែលត្រូវបានពន្យាបន្ត លុះត្រាតែអ្នកចុះកិច្ចសន្យាបានបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ :

(ក) អ្នកចុះកិច្ចសន្យាបានដាក់ពាក្យស្នើសុំពន្យាបន្តនៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែ យ៉ាងហោចណាស់ កៅសិប (៩០) ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែដែលកំពុងមាន

(ខ) អ្នកចុះកិច្ចសន្យាបានដាក់ជូនក្រសួងពិនិត្យនូវរបាយការណ៍ដូចខាងក្រោម :

១-របាយការណ៍លំអិតស្តីពីលទ្ធផលនៃការស្វែងរុករករ៉ែក្នុងរយៈពេលស្វែងរុករកមុន

២-កម្មវិធីការងារស្វែងរុករក និង ថវិកា ដែលបានស្នើឡើងសំរាប់ការពន្យាបន្តនៃរយៈពេលស្វែងរុករក

៣-កម្មវិធីបណ្តុះបណ្តាល

(គ) អ្នកចុះកិច្ចសន្យាបានបង់ជូនរដ្ឋចប់សព្វគ្រប់នូវថ្លៃឈ្នួលដីសម្បទាន ពន្ធនិងពន្ធដារ ថ្លៃឈ្នួល និងបន្ទុកចំណាយផ្សេងទៀតដូចបានចែងក្នុងជំពូកទី ៦ នៃកិច្ចព្រមព្រៀងនេះ ហើយដាក់ជូនក្រសួងពិនិត្យនូវរាល់សក្ខីប័ត្រ ឬភស្តុតាងដែលបញ្ជាក់ពីការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុនោះ និង

(ឃ) អ្នកចុះកិច្ចសន្យាបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវផ្សេងទៀត ដូចមានចែងក្នុងកិច្ចព្រម-ព្រៀងនេះ ។

៧.២ នៅចុងបញ្ចប់នៃឆ្នាំទីប្រាំមួយ (០៦) ឬ ឆ្នាំចុងក្រោយនៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែ ក្រសួងអាចយល់ព្រមដល់ការពន្យាបន្តនៃអាជ្ញាប័ណ្ណនេះសំរាប់រយៈពេលបន្ថែមកំណត់មួយក្នុងករណីដែលអ្នកចុះកិច្ចសន្យាត្រូវការពេលវេលាដើម្បីសិក្សាពីលទ្ធភាពសេដ្ឋកិច្ចនៃជំរករ៉ែនេះឬដើម្បីបន្តដាក់ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែនៅក្នុងតំបន់មានអាជ្ញាប័ណ្ណស្វែងរុករករ៉ែនោះ ។

១០.២ អ្នកចុះកិច្ចសន្យាត្រូវដាក់ជូនក្រសួងពិនិត្យក្នុងកំឡុងពេលកៅសិប (៩០) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ នូវរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រតិបត្តិការរ៉ែ ។ រាល់របាយការណ៍ទាំងអស់ត្រូវបញ្ចូលពតិមានដែលក្រសួងបានកំណត់ ។

១០.៣ អ្នកចុះកិច្ចសន្យាត្រូវប្រគល់ជូនក្រសួងនូវរាល់របាយការណ៍ទិន្នន័យ និងពតិមាន និងការសិក្សាវិភាគនិងបំណកស្រាយទិន្នន័យដែលទាក់ទងទៅនឹងតំបន់កិច្ចសន្យា និងកិច្ចប្រតិបត្តិការរ៉ែដែលតម្រូវតាមលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះក្នុងកំឡុងពេលដែលបានកំណត់ដោយក្រសួង ។

## ជំពូកទី ៥

## ភារកិច្ចហិរញ្ញវត្ថុ

### ប្រការ ១១ : ឈ្នួលដីសម្បទាន

អ្នកចុះកិច្ចសន្យាត្រូវបង់ជូនរាជរដ្ឋាភិបាលនូវឈ្នួលដីប្រចាំឆ្នាំ សំរាប់តំបន់មានអាជ្ញាប័ណ្ណស្វែងរុករករ៉ែ ក្នុងកំឡុងពេលសាមសិប(៣០)ថ្ងៃសំរាប់ឆ្នាំដំបូង បន្ទាប់ពីកាលបរិច្ឆេទចេញអាជ្ញាប័ណ្ណស្វែងរុករករ៉ែ និងសំរាប់ឆ្នាំបន្តបន្ទាប់ក្នុងអំឡុងខែទីមួយនៃឆ្នាំប្រតិទិននៅធនាគារជាតិនៃកម្ពុជា ហើយលេខគណនីធនាគាររបស់ក្រសួងនឹងត្រូវផ្តល់ជូននៅពេលមានសំណើរបស់អ្នកចុះកិច្ចសន្យា ។

ឈ្នួលដីប្រចាំឆ្នាំ សំរាប់រយៈពេលស្វែងរុករករ៉ែត្រូវបានកំណត់ដូចខាងក្រោម :

- ឆ្នាំទី ១-២ : ២០(ម្ភៃ) ដុល្លារអាមេរិក ក្នុងមួយគីឡូម៉ែត្រក្រឡាក្នុងមួយឆ្នាំ
- ឆ្នាំទី ៣-៤ : ៤០(សែសិប) ដុល្លារអាមេរិក ក្នុងមួយគីឡូម៉ែត្រក្រឡាក្នុងមួយឆ្នាំ
- ពីឆ្នាំទី ៥-៦: ៥០(ហាសិប) ដុល្លារអាមេរិក ក្នុងមួយគីឡូម៉ែត្រក្រឡាក្នុងមួយឆ្នាំ

### ប្រការ ១២ : ថ្លៃឈ្នួល និងបន្ទុកចំណាយផ្សេងៗ

១២.១. អ្នកចុះកិច្ចសន្យាត្រូវបង់ថ្លៃចុះបញ្ជីការ ថ្លៃពន្យាបន្ត ថ្លៃផ្ទេរសិទ្ធិ ថ្លៃខូចខាតព្រៃឈើ និងថ្លៃឈ្នួលព្រមទាំងបន្ទុកចំណាយផ្សេងទៀត សំរាប់ការអនុវត្តការងារទូទៅ ។

១២.២. អ្នកចុះកិច្ចសន្យាត្រូវចេញប្រាក់ចំណាយទូទៅសំរាប់សេវាកម្មផ្សេងៗ ដែលរាជរដ្ឋាភិបាលបានបំពេញទៅតាមសំណូមពររបស់អ្នកចុះកិច្ចសន្យា លើកលែងចំពោះសេវាកម្មណាដែលរាជរដ្ឋាភិបាលត្រូវបំពេញជាធម្មតា ។

Draft

**ប្រការ ១៣ : បទប្បញ្ញត្តិ ឬប្រកាសក្រសួង ឬអន្តរក្រសួង**

ភាគីទាំងបានយល់ព្រមថានៅពេលបទប្បញ្ញត្តិ ឬប្រកាសក្រសួង ឬ អន្តក្រសួងស្តីពីអត្រាសួយសារឈ្នួលដីប្រចាំឆ្នាំឬថ្លៃឈ្នួលពាក់ព័ន្ធផ្សេងទៀតចូលជាធរមាន រាល់អត្រាទាំងអស់ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងត្រូវធ្វើការកែសំរួលឱ្យស្របទៅតាមបទប្បញ្ញត្តិ ឬប្រកាសក្រសួង ឬអន្តរក្រសួងនោះ ។

## ជំពូកទី ៦

## ភាតព្វកិច្ចផ្តល់ការងារដល់ពលរដ្ឋកម្ពុជា និងការបណ្តុះបណ្តាល

**ប្រការ ១៤ : ភាតព្វកិច្ចផ្តល់ការងារដល់ពលរដ្ឋកម្ពុជា និង ការបណ្តុះបណ្តាល**

១៤.១ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ការងារអោយបានអតិបរមាជូនពលរដ្ឋកម្ពុជា តាមជំនាញសមស្របក្នុងកិច្ចប្រតិបត្តិការរ៉ែដោយគិតតាមលក្ខណៈសម្បត្តិ និងការបំពេញការងាររបស់បុគ្គលិកនោះដែលតំរូវតាមបទដ្ឋានរបស់អ្នកចុះកិច្ចសន្យាសំរាប់និយោជិកកម្ពុជា។ អ្នកចុះកិច្ចសន្យាត្រូវធ្វើកម្មវិធីអប់រំ និងបណ្តុះបណ្តាលដល់និយោជិកកម្ពុជារបស់អ្នកចុះកិច្ចសន្យា ដែលពុំទាន់មានបទពិសោធន៍ក្នុងកិច្ចប្រតិបត្តិរ៉ែដើម្បីធានាបានជាអតិបរិមានូវការចូលរួមពីពលរដ្ឋកម្ពុជា ក្នុងកិច្ចប្រតិបត្តិការរ៉ែនៅគ្រប់កំរិត ។ កម្មវិធីការងារស្វែងរុករកនីមួយៗ និងថវិកាសំរាប់កម្មវិធីស្វែងរុករកត្រូវមានកម្មវិធីបណ្តុះបណ្តាលដែលបានកំណត់ឡើង ជាជំហានៗដែលអ្នកចុះកិច្ចសន្យាមានបំណងអនុវត្ត ។

១៤.២ នៅក្នុងឆ្នាំនីមួយៗនៃរយៈពេលប្រតិបត្តិការរ៉ែ អ្នកចុះកិច្ចសន្យាត្រូវចំណាយនូវទឹកប្រាក់ចំនួន ៥០០០ (ប្រាំពាន់)ដុល្លារអាមេរិក តាមការណែនាំពីក្រសួង សំរាប់ការអប់រំ និងបណ្តុះបណ្តាលដល់និយោជិកក្រសួង (ដែលមិនមែនជានិយោជិករបស់អ្នកចុះកិច្ចសន្យា) លើវិស័យអភិវឌ្ឍន៍ធនធានរ៉ែ ។ មូលនិធិនេះត្រូវយកមកប្រើប្រាស់សំរាប់ការបណ្តុះបណ្តាលដល់បុគ្គលិកក្រសួង អាហារូបករណ៍ ការប្រជុំ និងទិញឧបករណ៍ផ្សេងៗ ។ ចំណែកណាមួយនៃមូលនិធិបណ្តុះបណ្តាលដែលមិនបានចំណាយនៅដំណាច់នៃឆ្នាំប្រតិទិន អាចយោងទៅសំរាប់ឆ្នាំប្រតិទិនបន្ទាប់ ឬបង់មកក្រសួងតាមឆន្ទានុសិទ្ធិរបស់ក្រសួង ។

១៤.៣ អ្នកចុះកិច្ចសន្យាយល់ព្រមផ្តល់ការបណ្តុះបណ្តាលនៅនឹងកន្លែងសំរាប់បុគ្គលិករបស់ក្រសួងដែលត្រូវផ្ទេរឱ្យទៅបំពេញភារកិច្ចបណ្តោះអាសន្នជាមួយអ្នកចុះកិច្ចសន្យាដើម្បីទទួលបទពិសោធន៍ក្នុងវិស័យអនុវត្តឧស្សាហកម្មជីកយករ៉ែដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការរ៉ែនៅព្រះរាជាណាចក្រកម្ពុជា។ ចំនួន និងការជ្រើសរើសបុគ្គលិកអោយទៅបំពេញភារកិច្ចបណ្តោះអាសន្ន និងរយៈពេលនៃការចាត់តាំងបណ្តោះអាសន្នរបស់

បុគ្គលិកទាំងនោះត្រូវអនុលោមទៅតាមការព្រមព្រៀងគ្នា ។ ភាគីទាំងពីរយល់ថាកិរិតនៃការយល់ដឹង និង ការបំពេញភារកិច្ចរបស់បុគ្គលិកនោះ ត្រូវតម្រូវតាមបទដ្ឋានរបស់អ្នកចុះកិច្ចសន្យាសំរាប់និយោជិកកម្ពុជា ។ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ប្រាក់កំរៃសមស្របដល់បុគ្គលិក ដែលត្រូវបានចាត់បញ្ជូនឱ្យទៅបំពេញភារៈកិច្ច បណ្តោះអាសន្ននោះ ហើយប្រាក់កំរៃនេះត្រូវបានចាត់ទុកជាសោហ៊ុយរ៉ែ ។

## ប្រការ ១៥ : សិទ្ធិក្នុងការជ្រើសរើសអ្នកឯកទេសបរទេស

១៥.១. អ្នកចុះកិច្ចសន្យា អ្នកចុះកិច្ចសន្យាបន្ត និង ភ្នាក់ងាររបស់ខ្លួន អាចជួលអ្នកឯកទេសបរទេសបាន លុះត្រា តែមិនអាចរកបាននូវបុគ្គលិកកម្ពុជាដែលមានជំនាញក្នុងការងារនោះ ដើម្បីបំពេញតួនាទីដែលត្រូវការ ។ ប៉ុន្តែអ្នកចុះកិច្ចសន្យាត្រូវប្រឹងប្រែងអោយអស់លទ្ធភាព ដើម្បីធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាអាចបំពេញការងារ នោះបាន ។

១៥.២. អ្នកឯកទេសបរទេសដែលជួលដោយអ្នកចុះកិច្ចសន្យាឱ្យមកធ្វើការលើសពីរយៈពេលប្រាំមួយ(៦)ខែ ត្រូវ បង់ពន្ធអាករសមស្រប ដោយអនុលោមតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី ៧

# ការការពារបរិស្ថាន

## ប្រការ ១៦ : ការស្តារឡើងវិញ និងសុវត្ថិភាព

បន្ទាប់ពីការបិទជាស្ថាពរនូវប្រតិបត្តិការរ៉ែ អ្នកចុះកិច្ចសន្យាត្រូវទទួលខុសត្រូវក្នុងការស្តារតំបន់នោះ ឡើងវិញអោយមានស្ថានភាពសមស្រប និងការពារការហូរច្រោះដី ហើយត្រូវធានាអោយមានសុវត្ថិភាពសំរាប់ តំបន់នោះដោយអនុលោមតាមការអនុវត្តនីផែនការសិក្សាស្រាវជ្រាវរ៉ែដែលត្រូវបានទទួលស្គាល់ និងតាមផែនការ ស្តារឡើងវិញដែលបានយល់ព្រម ។

## ប្រការ ១៧ : ប្រជាពលរដ្ឋក្នុងតំបន់

១៧.១ អ្នកចុះកិច្ចសន្យា អ្នកចុះកិច្ចសន្យាបន្ត ភ្នាក់ងារ និងបុគ្គលិករបស់ខ្លួនត្រូវគោរពតាមទំនៀមទំលាប់របស់ ប្រជាពលរដ្ឋដែលតាំងលំនៅដ្ឋាននៅក្នុងតំបន់កិច្ចសន្យា ហើយមិនត្រូវរំខាននិងជ្រៀតជ្រែកចូលក្នុងបេក្ខ- ខ័ណ្ឌជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះឡើយ ។

Draft

១៧.២ សំរាប់ការផ្លាស់ប្តូរលំនៅដ្ឋានថ្មីរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់កិច្ចសន្យា អ្នកចុះកិច្ចសន្យាត្រូវគោរព និង អនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ភូមិបាលដែលមានជាធរមាន ។

## ប្រការ ១៨ : ការការពារបរិស្ថានធម្មជាតិ

អ្នកចុះកិច្ចសន្យាត្រូវខិតខំប្រឹងប្រែងអោយអស់លទ្ធភាព ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវការប៉ះ-ពាល់ជាអវិជ្ជមានក្នុងប្រតិបត្តិការរ៉ែរបស់ខ្លួនលើលក្ខខ័ណ្ឌបរិស្ថានធម្មជាតិក្នុងតំបន់ទាំងនោះ ព្រមទាំងចាត់វិធាន-ការលើស្តារឡើងវិញនៅគ្រប់ពេលមុនការប្រគល់សងវិញនូវផ្ទៃក្រឡានៃតំបន់នោះ ដូចជាការចាំបាច់ដើម្បីការពារការហូរច្រោះដី ការបំពុលទឹក និងអាកាស ព្រមទាំងការថែរក្សាដល់ផលដំណាំ និងជីវិតសត្វព្រៃ ។

ជាពិសេសអ្នកចុះកិច្ចសន្យាត្រូវអនុវត្តប្រតិបត្តិការរ៉ែរបស់ខ្លួនអោយបានសមស្រប ដើម្បីចៀសវាងការបង្កឱ្យមានភាពកខ្វក់ដល់ការផ្គត់ផ្គង់ទឹកនៅលើដី និងនៅក្រោមដី ការការពារការហូរច្រោះដី និងការអន្តរាយដោយសារទឹកជំនន់ឱ្យបានជាអតិបរមា ព្រមទាំងការឈូសឆាយផ្ទៃដីអោយបានរាបស្មើ និងការដាំដើមឈើលំអ និងតំបន់សំរាប់ចោលកាកសំណល់ឱ្យបានសមស្រប ។

បន្ថែមទៅលើការធានារ៉ាប់រងអនុវត្តទូទៅដូចបានកំណត់ខាងលើ អ្នកចុះកិច្ចសន្យាត្រូវអនុវត្តទៅតាមផែនការនៃការស្តារឡើងវិញដែលបានយល់ព្រម និង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

## ប្រការ ១៩ : ការដ្ឋានដែលត្រូវហាមឃាត់

ត្រូវហាមឃាត់ជាដាច់ខាតមិនឱ្យធ្វើប្រតិបត្តិការរ៉ែ ក្នុងបរិវេណដែលមានកេរ្តិ៍ដំណែលបេតិកភ័ណ្ឌពីបុរាណ និងសម្បត្តិប្រវត្តិសាស្ត្រ ទីកន្លែងសក្ការៈបូជា កន្លែងបញ្ចុះសព ផ្លូវដែក ផ្លូវសាធារណៈ ស្រះ និងដីដែលបំរុងសំរាប់គោលបំណងសាធារណៈពិសេសផ្សេងទៀត ទោះបីតំបន់ទាំងនោះឋិតនៅក្នុងតំបន់កិច្ចសន្យានេះក៏ដោយ លើកលែងតែអ្នកចុះកិច្ចសន្យាបានទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរពិសេសពីក្រសួង បន្ថែមលើអាជ្ញាប័ណ្ណស្វែងរុករករ៉ែដែលនៅមានសុពលភាព ។

## ប្រការ ២០ : ការការពារភ្លើងឆេះព្រៃ

អ្នកចុះកិច្ចសន្យាត្រូវប្រុងប្រយ័ត្នការពារភ្លើងឆេះព្រៃ ហើយត្រូវផ្តល់ដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតជាបន្ទាន់ក្នុងករណីមានភ្លើងឆេះព្រៃកើតឡើង ។

### ប្រការ ២១ : ប្រតិបត្តិការកាប់ឈើ

អ្នកចុះកិច្ចសន្យាមិនត្រូវជ្រៀតជ្រែកចូលក្នុងប្រតិបត្តិការកាប់ឈើជាដាច់ខាតនៅក្នុងតំបន់កិច្ចសន្យា ។ ក្នុងករណីមានប្រតិបត្តិការកាប់ឈើនៅក្នុងតំបន់កិច្ចសន្យារបស់ខ្លួន អ្នកចុះកិច្ចសន្យាត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ដែលគ្រប់គ្រងតំបន់នោះជាបន្ទាន់ ។

### ប្រការ ២២ : ទឹកសំរាប់ប្រើប្រាស់

អ្នកចុះកិច្ចសន្យាត្រូវធ្វើបញ្ញតិដែលនឹងធានាថា ទឹកដែលបានប្រើប្រាស់ក្នុងប្រតិបត្តិការរ៉ែ មិនត្រូវបន្ថយបទដ្ឋានគុណភាពទឹកឡើយ មុនពេលដែលវាហូរចេញពីដីដែលទទួលឥទ្ធិពលពីការស្វែងរុករករ៉ែ ។ អ្នកចុះកិច្ចសន្យាគ្មានសិទ្ធិបន្ថយគុណភាព ឬបរិមាណនៃប្រភពទឹកមានស្រាប់ដែលកំពុងប្រើប្រាស់សំរាប់ការរស់នៅរបស់ប្រជា-ពលរដ្ឋក្នុងតំបន់ សំរាប់ការធ្វើកសិកម្ម ឬការចិញ្ចឹមសត្វ ដោយមិនបានខិតខំប្រឹងប្រែងឱ្យបានសមស្រប ដើម្បីផ្តល់ឱ្យអ្នកប្រើប្រាស់ទឹកនូវការផ្គត់ផ្គង់ទឹក និងប្រភពទឹកអាចប្រៀបធៀបគ្នាបាន ឬទូទាត់សំណងសមស្របឱ្យអ្នកប្រើប្រាស់ទឹក ។

## ជំពូកទី ៨

## ការព្យួរទុក និង/ឬ ការដកហូតអាជ្ញាប័ណ្ណរ៉ែ

### ប្រការ ២៣ : ការព្យួរទុក និង/ឬ ការដកហូតអាជ្ញាប័ណ្ណរ៉ែ

២៣.១ សំរាប់ករណីពុំទាន់មានអនុក្រឹត្យស្តីពីនីតិវិធីនៃការព្យួរទុក និងការដកហូតអាជ្ញាប័ណ្ណរ៉ែ ភាគីទាំងពីរបានព្រមព្រៀងគ្នាថា អាជ្ញាប័ណ្ណស្វែងរុករករ៉ែដែលចេញឱ្យអ្នកចុះកិច្ចសន្យាក្រោមលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ ត្រូវព្យួរទុកនិង/ឬត្រូវដកហូតក្នុងករណីដូចខាងក្រោម :

(ក) អាស្រ័យទៅលើកំរិតនៃការបំពានលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និង បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ដែលអ្នកចុះកិច្ចសន្យាបានប្រព្រឹត្ត និង

(ខ) របាយការណ៍ប្រតិបត្តិការរ៉ែ ដែលបានរាយការណ៍តាមកាលកំណត់មកក្រសួង មានលក្ខណៈមិនពិត ឬមិនត្រឹមត្រូវ ។

២៣.២ រយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណស្វែងរុករករ៉ែមិនត្រូវលើសពីប្រាំមួយ (០៦) ខែ ។

២៣.៣ អាស្រ័យទៅតាមកំរិតបំពានរបស់អ្នកចុះកិច្ចសន្យា ក្រសួងត្រូវចេញលិខិតណែនាំ ឬបទបញ្ជាជាកំណត់ ដើម្បីតម្រូវឱ្យអ្នកចុះកិច្ចសន្យាដោះស្រាយបញ្ហាពាក់ព័ន្ធ ឬជំរះបំណុលពាក់ព័ន្ធ ឬធ្វើការកែកំហុសរបស់



Draft

ខ្លួនក្នុងកំឡុងពេលកៅសិប(៩០)ថ្ងៃ បន្ទាប់ពីអ្នកចុះកិច្ចសន្យាបានទទួលលិខិតណែនាំ ឬបទបញ្ជានោះពីក្រសួង ។ បន្ទាប់ពីរយៈពេលកៅសិប(៩០)ថ្ងៃ ដូចបានកំណត់ខាងលើត្រូវបានផុតកំណត់ ហើយប្រសិនបើអ្នកចុះកិច្ចសន្យានៅតែមិនដោះស្រាយបញ្ហាពាក់ព័ន្ធ ឬជំរះបំណុលពាក់ព័ន្ធ ឬធ្វើការកែកំហុសរបស់ខ្លួនទៀត ក្រសួងត្រូវចេញប្រកាសស្តីពីការព្យួរទុកអាជ្ញាប័ណ្ណស្វែងរុករករ៉ែនោះ ។ នៅក្នុងកំឡុងពេលនៃការព្យួរទុកប្រាំមួយ(០៦)ខែចាប់ពីកាលបរិច្ឆេទចរមាន នៃ ប្រកាសស្តីពីការព្យួរទុកអាជ្ញាប័ណ្ណស្វែងរុករករ៉ែ រាល់សកម្មភាពទាំងអស់នៃកិច្ចប្រតិបត្តិការរ៉ែត្រូវព្យួរទុកជាបណ្តោះអាសន្នទៅតាមរយៈពេលនោះ ហើយអ្នកចុះកិច្ចសន្យាមានឱកាសចុងក្រោយដែលមានរយៈពេលប្រាំមួយ(០៦)ខែនេះ ដើម្បីបំពេញរាល់តម្រូវ-ការទាំងអស់ដែលបានកំណត់នៅក្នុងលិខិតណែនាំ ឬបទបញ្ជារបស់ក្រសួង ។ នៅពេលដែលអ្នកចុះកិច្ចសន្យាយល់ឃើញថា រាល់តម្រូវការទាំងអស់របស់ក្រសួងត្រូវបានបំពេញចប់សព្វគ្រប់អ្នកចុះកិច្ចសន្យាអាចដាក់សំណើដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការសន្យាអនុវត្តដែលបានបំពេញរួច ដើម្បីស្នើសុំអាជ្ញា-ប័ណ្ណស្វែងរុករករ៉ែ ដែលកំពុងស្ថិតនៅក្នុងរយៈពេលនៃការព្យួរទុកជូនមកក្រសួងដើម្បីពិនិត្យ និងសំរេចយ៉ាងហោចណាស់ឱ្យបានមុនសាមសិប(៣០)ថ្ងៃ មុននឹងផុតកំណត់សុពលភាពនៃប្រកាសស្តីពីការព្យួរទុកអាជ្ញាប័ណ្ណស្វែងរុករករ៉ែ ។ នៅពេលដែលរយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណស្វែងរុករករ៉ែត្រូវបានផុតសុពលភាព ហើយដែលក្នុងរយៈពេលនោះអ្នកចុះកិច្ចសន្យានៅតែខកខានមិនបានអនុវត្តទៀត ក្រសួងត្រូវចេញប្រកាសដើម្បីដកហូតអាជ្ញាប័ណ្ណស្វែងរុករករ៉ែពីអ្នកចុះកិច្ចសន្យា ។

២៣.៤ ក្នុងករណីអាជ្ញាប័ណ្ណស្វែងរុករករ៉ែត្រូវបានដកហូតក្រោមកិច្ចព្រមព្រៀងនេះ អ្នកចុះកិច្ចសន្យាត្រូវទទួលខុសត្រូវក្នុងការជំរះទូទាត់បំណុលពាក់ព័ន្ធទាំងអស់ដែលរួមមាន ឈ្នួលដីប្រចាំឆ្នាំ និងបន្ទុកចំណាយពាក់ព័ន្ធផ្សេងទៀត ។

## ជំពូកទី ៩

## ដំណោះស្រាយវិវាទ

### ប្រការ ២៤ : ការពិគ្រោះយោបល់

ក្រសួង និងអ្នកចុះកិច្ចសន្យាយល់ព្រមខិតខំដោះស្រាយបញ្ហាណាមួយដែលកើតមានឡើងពីកិច្ចព្រមព្រៀងនេះដោយមិត្តភាព ។

**ប្រការ ២៥ : មជ្ឈត្តវិនិច្ឆ័យ**

ប្រសិនបើវិវាទណាមួយមិនអាចដោះស្រាយដោយមិត្តភាព ដូចបានចែងក្នុងប្រការ ២៤ ខាងលើ ការវិវាទនោះនឹងត្រូវដោះស្រាយនៅព្រះរាជាណាចក្រកម្ពុជា ដោយមជ្ឈត្តវិនិច្ឆ័យមួយដែលស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០

## សេចក្តីបញ្ជាក់ផ្សេងៗ

**ប្រការ ២៦ : សេចក្តីជូនដំណឹង**

សេចក្តីជូនដំណឹងទាំងអស់ដែលតម្រូវឱ្យជូនដំណឹងដោយភាគីមួយទៅឱ្យភាគីមួយទៀត ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវតែជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ ឬអង់គ្លេស ហើយអាចធ្វើតាមប្រៃសណីយ៍ដោយបានបង់ប្រាក់រួច ឬតាមការផ្ញើរជាសំបុត្រ ឬតាមទូរសារដែលបញ្ជាក់ដោយប្រៃសណីយ៍ដោយបានបង់ប្រាក់រួច ឬ តាមការប្រគល់ផ្ទាល់ទៅអាស័យដ្ឋានរបស់ភាគីនីមួយៗ ដូចបានបង្ហាញខាងក្រោម ឬប្រគល់ទៅអាស័យដ្ឋានផ្សេងទៀតដែលភាគីនីមួយៗអាចជូនដំណឹងទៅពេលក្រោយទៅឱ្យភាគីម្ខាងទៀត ។សេចក្តីជូនដំណឹងទាំងអស់ត្រូវបានចាត់ទុកថាធ្វើឡើងដោយត្រឹមត្រូវនៅពេលដែលបានទទួល ។

**ក្រសួង :** **ជូនចំពោះ : រដ្ឋមន្ត្រី**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

៤៥ មហាវិថីព្រះនរោត្តម , ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរសារ : ៨៥៥-២៣-៤២៨ ២៦៣

**អ្នកចុះកិច្ចសន្យា :** ជូនចំពោះ : **លោក សាន ឈុនសុខ**

នាយកក្រុមហ៊ុន Samnang Rea Thbong Thunor Co., Ltd.

#០៩, ផ្លូវលេខ ៥៥៦ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ,

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ៨៥៥-២៣-៩៩១ ៨០១/១២-៩៥២ ៨៥៥/១៦-៨៨៥ ២៤២

Draft

## ប្រការ ២៧ : ទីស្នាក់ការ

ក្នុងកំឡុងពេលកៅសិប(៩០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទចរមាននៃកិច្ចព្រមព្រៀង អ្នកចុះកិច្ចសន្យាត្រូវបង្កើតទីស្នាក់ការតំណាងក្រុមហ៊ុនរបស់ខ្លួននៅភ្នំពេញ (ប្រសិនបើមិនទាន់មាន) ហើយត្រូវរក្សាទុកទីស្នាក់ការនេះក្នុងថេរៈវេលានៃកិច្ចប្រតិបត្តិការរ៉ែនេះ ។ក្នុងករណីមានការផ្លាស់ប្តូរអាស័យដ្ឋានទីស្នាក់ការ អ្នកចុះកិច្ចសន្យាត្រូវជូនដំណឹងដល់ក្រសួងក្នុងកំឡុងពេលមួយ(០១)សប្តាហ៍ ។

## ប្រការ ២៨ : ភាសាប្រើក្នុងកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងដោយភាគីទាំងពីរជាភាសាខ្មែរ និងភាសាអង់គ្លេសដែលភាសានីមួយៗមានតំលៃស្មើគ្នា និងមានសុពលភាពក្នុងការបកស្រាយ ប៉ុន្តែក្នុងករណីមានការខ្វែងគ្នារវាងភាសាទាំងពីរ អត្ថបទជាភាសាខ្មែរត្រូវចាត់ទុកជាគោល ។

ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះជាភាសាខ្មែរ និងភាសាអង់គ្លេស នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃដូចបានកំណត់ខាងលើ មួយមុខៗចំនួន ២ច្បាប់ដើម ។

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

29 NOV 2005

ស៊ុយ សែម

រដ្ឋមន្ត្រី

ក្រុមហ៊ុន SAMNANG REA THBONG THMOR CO., LTD.

29 NOV 2005

លោក សាន

ប្រធានក្រុមហ៊ុន